ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

**ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញធ្វើជាអធិបតីក្នុងពិធីសម្ពោធលេខាធិការដ្ឋានជាតិកម្ពុជា នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី **១០** ខែ**តុលា** ឆ្នាំ**២០១៧** នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ឯកឧត្តម ឯកអគ្គរាជ/រដ្ឋទូត ឬ តំណាងនៃបណ្តាប្រទេសមេគង្គ-ឡានឆាង ប្រចាំនៅកម្ពុជា រួមមាន មីយ៉ាន់ម៉ា ឡាវ ថៃ វៀតណាម និងចិន និងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ក៏នឹងអញ្ជើញចូលរួមក្នុងពិធីសម្ពោធខាងលើផងដែរ។

ពិធីសម្ពោធលេខាធិការដ្ឋានជាតិនេះ បង្ហាញពីការចូលរួមរបស់កម្ពុជា ជាមួយបណ្តាប្រទេសអាស៊ីអាគ្នេយ៍បួនទៀត ដែលមានទីតាំងភូមិសាស្ត្រនៅតាមបណ្តោយទន្លេមេគង្គ ក្នុងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសចិន ដើម្បីលើកកំពស់ការអភិវឌ្ឍនៅក្នុងតំបន់ ជាមួយគោលបំណងបង្កើតសហគមន៍ដែលមានអនាគតប្រកបដោយសន្តិភាព និងវិបុលភាព រួមគ្នាមួយ។

ចាប់តាំងពីត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៥ កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង បានអនុម័តការប្តូរវេនគ្នា រៀងរាល់ពីរឆ្នាំម្តងនៅក្នុងចំណោមប្រទេសដែលនៅតាមបណ្តោយទន្លេមេគង្គ ដើម្បីធ្វើសហប្រធានជាមួយប្រទេសចិន ដែលជាប្រធានអចិន្ត្រៃយ៍នៃទន្លេឡានឆាង នៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការនយោបាយ និងសន្តិសុខ ការសំរេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ក៏ដូចជាការជំរុញការផ្លាស់ប្តូរផ្នែកសង្គម វប្បធម៌ និងរវាងប្រជាជន ផងដែរ។

គួរកត់សម្គាល់ថា ក្នុងគោលបំណងពង្រឹងបន្ថែមទៀតយន្តការកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ប្រទេសទាំង៦នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង បានព្រមព្រៀងគ្នា នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសលើកទី២ កាលពីខែធ្នូ ឆ្នាំ ២០១៦ នៅខេត្តសៀមរាប បង្កើតឲ្យមានលេខាធិការដ្ឋានជាតិ/អង្គភាពសម្របសម្រួលមួយ នៅក្នុងក្រសួងការបរទេសនៃប្រទេសនីមួយៗ។ បន្ថែមពីនេះ ប្រទេសកម្ពុជា ក៏នឹងធ្វើជាម្ចាស់ផ្ទះ និងធ្វើសហប្រធានជាមួយប្រទេសចិន សំរាប់កិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី២ នៅក្នុងខែមករា ឆ្នាំ២០១៨ ខាងមុខនេះ ផងដែរ។៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៧

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh